■ គម្រោងគាំទ្រពាណិជ្ជូបនីយកម្មស្រូវអង្ករកម្ពុជា [SCCRP]
[ការផ្ដល់ជូនរបស់ AFD - CKH-1077-01-S និង CKH-1077-02-T]
AFD
ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ (SNEC)

ករណីសិក្សា #6

# ការប្រឹក្សាយោបល់របស់សហព័ន្ធអង្គការកសិករ ស្ដីពីក្របខណ្ឌច្បាប់សម្រាប់សហគមន៍កសិកម្ម

ថ្ងៃទី 25 ខែមករា ឆ្នាំ 2018

អ្នកនិពន្ធ៖ CHRISTOPHE GOOSSENS (ADG) សមាគម AVSF-CIRD-ADG CONSORTIUM[1]

## មាតិកា

1. ទិដ្ឋភាពរួម / ការបរិយាយខ្លីអំពីបរិបទ ........ 2
2. ដើមកំណើតសកម្មភាព ........ 2
3. ភាគីពាក់ព័ន្ធដែលចូលរួម ........ 4
4. ដំណើរការអនុវត្តន៍ ........ 4
5. លទ្ធផល និងស្ថានភាពប្រតិបត្តិការ ........ 6
6. អត្ថប្រយោជន៍ ........ 8

## អក្សរកាត់

| | |
|---|---|
| AC | សហករណ៍កសិកម្ម |
| ADG | *Aide au Développement - Gembloux* |
| AFD | *ទីភ្នាក់ងារអភិវឌ្ឍន៍បារាំង* |
| AVSF | *អង្គការក្សេត្រសាស្ត្រ និងពេទ្យសត្វគ្មានព្រំដែន* |
| CIRD | វិទ្យាស្ថានកម្ពុជាសម្រាប់ស្រាវជ្រាវ និងអភិវឌ្ឍន៍ជនបទ |
| DACP | នាយកដ្ឋានអភិវឌ្ឍន៍សហគមន៍កសិកម្ម (GDA/MAFF) |
| DGRV | សហព័ន្ធសហករណ៍រាយហ្វេសិន អាលីម្លង់ |
| FAEC | សហព័ន្ធសមាគមកសិករជំរុញសហគ្រាសកសិកម្មជាលក្ខណៈគ្រួសារនៅកម្ពុជា |
| FCFD | សហព័ន្ធអង្គការកសិករកម្ពុជាដើម្បីអភិវឌ្ឍន៍ |
| FO | អង្គការកសិករ |
| MAFF | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ |
| NGO | អង្គការមិនមែនរដ្ឋាភិបាល |
| SNEC | ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ |
| SCCRP | គម្រោងគាំទ្រពាណិជ្ជូបនីយកម្មស្រូវអង្ករកម្ពុជា |
| U-AC | សហគមន៍កសិកម្ម |

[1]www.avsf.org ; http://www.cird.org.kh ; http://www.ong-adg.be

សេចក្ដីបដិសេធ៖ ឯកសារនេះបង្ហាញតែពីទស្សនៈរបស់អ្នកនិពន្ធប៉ុណ្ណោះ ពុំមែនជាទស្សនៈរបស់ AFD ឬ SNEC ឡើយ។

## 1. ទិដ្ឋភាពរួម / ការបរិយាយខ្លីអំពីបរិបទ

គម្រោងគាំទ្រពាណិជ្ជូបនីយកម្មស្រូវអង្ករកម្ពុជា (SCCRP) បានទទួលមូលនិធិពីទីភ្នាក់ងារអភិវឌ្ឍន៍បារាំង (AFD) ដែលអនុវត្តដោយឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ច (SNEC) និងមានជំនួយពីអ្នកផ្តល់ប្រឹក្សាមកពី IRAM/NIRAS និងបុគ្គលិកសមភាគីមកពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (MAFF)។ ក្រុមអ្នកផ្តល់ប្រឹក្សាពី AVSF, ADG និង CIRD បានទទួលខុសត្រូវលើការគាំទ្រ និងការពង្រឹងបណ្តាញ និងសហព័ន្ធអង្គការកសិករជាលក្ខណៈស្ថាប័ន។

ករណីសិក្សានេះ ធ្វើឡើងដើម្បីចងក្រងឯកសារអំពីដំណើរការប្រឹក្សាយោបល់របស់អ្នកតំណាងអង្គការកសិករ និងអំពីការត្រួតពិនិត្យរបស់សហព័ន្ធ FAEC និង FCFD ទៅលើក្របខណ្ឌច្បាប់ព្រាងស្តីពីលក្ខន្តិកៈគំរូ ច្បាប់ និងបទបញ្ញត្តិផ្ទៃក្នុងរបស់សហគមន៍កសិករ (U-AC) ដែលរៀបចំឡើងដោយ MAFF និងមានការគាំទ្រពី DGRV ។ ក្រសួង MAFF បានចេញច្បាប់ស្តីពីសហគមន៍កសិករ (AC) នៅឆ្នាំ 2013 ។ បន្ថែមពីលើការប្រកាសច្បាប់នេះ អនុក្រឹត្យ និងបទបញ្ញត្តិមួយចំនួននៅតែតម្រូវឱ្យបំពេញបន្ថែមលើក្របខណ្ឌអនុក្រិត្យ និងច្បាប់ស្តីពី AC ។ នៅក្នុងចំណោមចំណុចទាំងនោះ គឺ "លក្ខន្តិកៈគំរូ ច្បាប់ និងបទបញ្ញត្តិផ្ទៃក្នុងរបស់ U-AC (មាត្រា 95 នៃច្បាប់ AC)។ ការរៀបចំច្បាប់នេះ គឺមានការគាំទ្រពី DGRV (*Deutscher Genossenschafts und Raiffeisenverband* – សហព័ន្ធសហករណ៍រាយហ្វេសិន អាល្លឺម៉ង់) ដែលឧបត្ថម្ភការរៀបចំក្របខណ្ឌច្បាប់ផ្សេងទៀតដោយ DACP ។ ការប្រឹក្សាយោបល់របស់អង្គការកសិករមិនត្រូវបានប៉ាន់ស្មានដោយ DGRV ឬ DACP នៅពេលរៀបចំក្របខណ្ឌច្បាប់ទេ។

ក្រុមគណៈគ្រប់គ្រងគម្រោង SCCRP បានចាត់ទុកការប្រឹក្សាយោបល់របស់អ្នកតំណាងកសិករមានសារៈសំខាន់ក្នុងការសម្រេចបានគោលបំណងជំរុញអភិវឌ្ឍសង្វាក់តម្លៃកសិកម្មឱ្យកាន់តែទូលំទូលាយដោយដោះស្រាយបរិយាកាសអាជីវកម្មឱ្យបានត្រឹមត្រូវ។ លើសពីនេះទៅទៀត អ្នកតំណាងកសិករបានតវ៉ាថា តួនាទីពួកគេជាភាគីពាក់ព័ន្ធសេដ្ឋកិច្ចក្នុងវិស័យឯកជន គឺនៅមានកម្រិត និងមិនត្រូវបានទទួលស្គាល់ ដោយសារគោលនយោបាយនោះមិនមែនធ្វើឡើងសម្រាប់អត្ថប្រយោជន៍អាជីវកម្មរបស់ពួកគេទេ។ ប៉ុន្តែ DACP បានចាប់ផ្តើមទទួលស្គាល់ថាការប្រឹក្សាយោបល់នោះមានប្រយោជន៍ក្នុងការផ្តល់ការយល់ដឹងបឋមស្តីពីច្បាប់ និងបទបញ្ញត្តិ ដែលនាំឱ្យសម្រេចបាននូវកម្រិតនៃគណនេយ្យភាពរបស់អ្នកដឹកនាំ AC ដែលបានប្រឹក្សាយោបល់។

## 2. ដើមកំណើតសកម្មភាព

គម្រោង SCCRP បង្កើតឡើងដោយផ្អែកលើគោលនយោបាយនាំចេញស្រូវអង្កររបស់រាជរដ្ឋាភិបាលកម្ពុជា (RGC) ដែលសម្រេចនៅក្នុងផែនការសកម្មភាព និងយុទ្ធសាស្ត្រអភិវឌ្ឍន៍អនុវិស័យស្រូវអង្ករ។ ក្នុងចំណោមចំណុចទាំងនោះគឺជាការគាំទ្រ និងការពង្រឹងបណ្តាញ និងសហព័ន្ធអង្គការកសិករជាលក្ខណៈស្ថាប័ន (ស្ថិតក្រោមសមាសភាគ 1 របស់ SCCRP) ដែលមានគោលបំណងលើកកម្ពស់ស្ថានភាពសម្រាប់កិច្ចសន្ទនា និងកិច្ចសហប្រតិបត្តិការរវាងភាគីពាក់ព័ន្ធផ្សេងៗ ក្នុងសង្វាក់តម្លៃស្រូវអង្ករ ដើម្បីលើកកម្ពស់ និងគាំទ្រដល់ភាពដៃគូ ក៏ដូចជាកិច្ចសន្ទនាឯកជន និងសាធារណៈក្នុងវិស័យស្រូវអង្ករ។

គម្រោងនេះ គឺមានគោលបំណងគាំទ្រលើការរៀបចំកិច្ចសន្ទនាជាសារធារណៈ និងឯកជន ដែលក្រុមគណៈគ្រប់គ្រង SCCRP បានបង្កើតការរៀបចំសិក្ខាសាលាប្រឹក្សាយោបល់ជាមួយអ្នកតំណាងសហព័ន្ធ FO និង AC ។ ឱកាសនៃការ

រៀបចំ DACP លើក្របខណ្ឌច្បាប់ AC-U ត្រូវបានទទួលយកនៅឆ្នាំ 2014 ដើម្បីរៀបចំដំណើរការប្រឹក្សាយោបល់ដោយ FAEC និង FCFD ដោយយោងតាមសេចក្តីព្រាងស្តីពីច្បាប់សម្រាប់សហគមន៍ AC ដែលរៀបចំដោយក្រសួង MAFF និងការបញ្ជូនមតិ និងការស្នើសុំទៅក្រសួង MAFF ស្តីពីបញ្ហានេះ។

ជាដំបូង គម្រោង SCCRP បានស្នើសុំគាំទ្រដំណើរការការបង្កើតសមាសធាតុផ្សេងៗគ្នានៃសំណុំបទបញ្ញត្តិ DACP បន្ថែមដូចជា៖

- អនុក្រិត្យស្តីពីការរៀបចំ និងដំណើរការមូលនិធិអភិវឌ្ឍ AC (ACDF)
- អនុក្រិត្យស្តីពីការប្រព្រឹត្តិចំពោះ និងការលើកចិត្តបន្ថែម ដែល AC អាចទទួលពី RGC
- គោលការណ៍ណែនាំស្តីពីកិច្ចព្រមព្រៀងកសិកម្មតាមកិច្ចសន្យាសម្រាប់ធ្វើអាជីវកម្មរបស់ AC

ផែនទីផ្លូវជាក់លាក់ត្រូវបានធ្វើឡើង រួមមានការរៀបចំពេលវេលានៃធាតុចូល SCCRP ស្តីពីប្រធានបទខុសៗគ្នា។ ការរៀបចំទាំងនេះបានចាប់ផ្តើមឡើងដោយការបង្កើត "ក្រុមប្រឹក្សាគោលនយោបាយ AC" ដែលជាការប៉ាន់ស្មានក្នុងច្បាប់ AC (ជំពូក II ផ្នែក 1) ជាមួយនឹងគោលបំណងរៀបចំបទបញ្ញត្តិ គោលនយោបាយ ផែនការយុទ្ធសាស្ត្រសម្រាប់ការអភិវឌ្ឍរបស់ AC ។ យោងតាមការអនុម័តពីគណៈគ្រប់គ្រងគម្រោង ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងទីភ្នាក់ងារបារាំង ជំនួយបច្ចេកទេសគឺចាត់ទុកថាជាការបំពេញបន្ថែមលើដំណើរការចូលរួម ដើម្បីបរិយាយបទបញ្ញត្តិទាំងនេះ។ ប៉ុន្តែសំណើដ៏ធំទូលាយនេះគឺមិនមានចម្លើយពី MAFF និង AFD ទេ។

ជាពិសេស សិក្ខាសាលាអំពីការប្រឹក្សាយោបល់ជាមួយសហព័ន្ធ FO និងអ្នកតំណាង AC ស្តីពីក្របខណ្ឌច្បាប់ AC-U គឺដើម្បីទាញយកបទពិសោធន៍ដែលមានប្រយោជន៍សម្រាប់ដំណើរការរៀបចំក្របខណ្ឌច្បាប់បន្ថែម ក៏ដូចជាជំរុញឱ្យមានគំនិតផ្តួចផ្តើម DACP ដើម្បីរៀបចំយន្តការតាមរយៈបញ្ហាផ្សេងៗដែលអាចមានដំណើរការនៅក្នុងវិធីសាស្ត្រពហុភាគីពាក់ព័ន្ធ និងភាពជាដៃគូជាមួយអ្នកតំណាង AC ។ គោលនយោបាយចម្បងត្រូវបានបង្ហាញសម្រាប់កិច្ចព្រមព្រៀងជាមួយ DACP ៖

- តម្លាភាពពេញលេញលើដំណើការ សកម្មភាព និងការសម្របសម្រួលពាក់ព័ន្ធនឹង DACP និងដៃគូផ្សេងៗ។
- ការប្រឹក្សាយោបល់លក្ខណៈជាប្រព័ន្ធជាមួយអ្នកតំណាងសហករណ៍ AC និងការអន្តរាគមន៍មានកម្រិតក្នុងការពិភាក្សាផ្ទៃក្នុងសហព័ន្ធអង្គការ FO លើខ្លឹមសារគោលនយោបាយ
- ផ្តល់ព័ត៌មានទាន់ពេលវេលា និងផ្តល់សេចក្តីព្រាងអត្ថបទច្បាប់វែងទុកជាមុន ដើម្បីអនុញ្ញាតឱ្យសហព័ន្ធអង្គការ FO អាចរៀបចំការប្រឹក្សាយោបល់ផ្ទៃក្នុង និងបង្កើតតួនាទីពាក់ព័ន្ធដែលទូលំទូលាយ។

ទោះជាយ៉ាងណាក៏ដោយ ក៏គម្រោង SCCRP គាំទ្រដល់សហព័ន្ធអង្គការ FO ក្នុងការពិនិត្យមើលឡើងវិញនូវការបង្កើតក្របខណ្ឌគតិយុទ្ធស្របតាមគោលបំណងរួម ដើម្បីកសាងសមត្ថភាពរបស់សហព័ន្ធអង្គការ FO និងអ្នកតំណាងសហករណ៍ AC ដើម្បី "ធ្វើការវិភាគ និងប្រាស្រ័យទាក់ទងប្រកបដោយប្រសិទ្ធភាព" ។ បញ្ហារបស់សហករណ៍ AC-U គឺជាក្តីបារម្ភជារួមរវាងអ្នកតំណាងទាំងនេះ និងនាយកដ្ឋានអភិវឌ្ឍន៍សហគមន៍កសិកម្ម និងរាជរដ្ឋាភិបាលកម្ពុជា។ ក្រុមការងាររបស់គម្រោង SCCRP បានចាប់ផ្តើមដំណើរការប្រឹក្សាយោបល់ក្នុងរយៈពេល 3 ទៅ 4 ខែ ក្នុងនោះរួមមាន ការ

ប្រឹក្សាយោបល់តាមបែបវិមជ្ឈការនៅថ្នាក់ខេត្ត ជាពិសេសគឺកន្លែងដែលសហករណ៍ AC បានទទួលរ៉ាប់រងលើមុខងារជាសមូហភាពក្រៅផ្លូវការក្នុងចំណោមកន្លែងទាំងនោះ។ ប៉ុន្តែ ក្រសួងកសិកម្ម រុក្ខាប្រម៉ាញ់ និងនេសាទ បានពន្យារពេលផ្តល់សេចក្តីព្រាងឯកសារច្បាប់ និងដាក់កាលបរិច្ឆេទកំណត់ច្បាស់លាស់ក្នុងការផ្តល់ព័ត៌មានដែលមិនមានពេលគ្រប់គ្រាន់សម្រាប់រៀបចំសិក្ខាសិលាថ្នាក់ខេត្តទាំងនេះ ហើយមានតែការពិភាក្សាមួយដំណាក់ត្រូវបានរៀបចំជាមួយអ្នកដឹកនាំអង្គការដែលបានជ្រើសរើសនៅក្នុងទីក្រុងភ្នំពេញ។ ការដាក់កម្រិតនេះបានធ្វើឱ្យកិច្ចពិភាក្សាមានភាពមិនល្អ ទោះបីជាមានការចូលរួមចំណែកពីសហព័ន្ធអង្គការ FO និងអ្នកតំណាងសហករណ៍ AC ក៏ដោយ។

## 3. ភាគីពាក់ព័ន្ធដែលចូលរួម

ការត្រួតពិនិត្យគោលនយោបាយឡើងវិញដោយក្រុមភ្នាក់ងារពាក់ព័ន្ធសំខាន់ៗចំនួនបួនដូចខាងក្រោម៖

**តារាងទី 1៖ ភ្នាក់ងារពាក់ព័ន្ធនៅក្នុងការត្រួតពិនិត្យឡើងវិញ**

| ភាគីពាក់ព័ន្ធ | តួនាទី / មុខងារ | ភារកិច្ចចម្បង |
|---|---|---|
| សហព័ន្ធអង្គការកសិករចំនួន 2 (FAEC, FCFD) | វិភាគ ប្រាស្រ័យទាក់ទង | វិភាគគោលនយោបាយ ចូលរួមចំណែកផ្តល់មតិយោបល់ចំពោះខ្លឹមសាររបស់វា<br>ទាក់ទងជាមួយអ្នកតំណាងអង្គការកសិករ<br>រួមបញ្ចូលលទ្ធផលនៃការពិគ្រោះយោបល់ផ្ទៃក្នុង<br>បញ្ជូនលទ្ធផលទៅ DACP/MAFF |
| នាយកដ្ឋានអភិវឌ្ឍន៍សហគមន៍កសិកម្ម | អញ្ជើញភ្ញៀវធ្វើកិច្ចពិភាក្សាសាធារណៈ-ឯកជន | បញ្ជូនក្របខណ្ឌច្បាប់ព្រាង<br>ត្រួតពិនិត្យមតិយោបល់ពី FO- Feds (និងពិចារណាលើមតិយោបល់ទាំងនោះ នៅពេលបញ្ចប់ក្របខណ្ឌច្បាប់)<br>សម្របសម្រួលជាមួយដៃគូ ធ្វើការជាក្រុម... |
| អ្នកប្រឹក្សាយោបល់គម្រោង SCCRP | ជំនួយការបច្ចេកទេស | ជំនួយការបច្ចេកទេសទៅអ្នកតំណាង FO-Feds<br>ការគាំទ្រហិរញ្ញវត្ថុសម្រាប់ដំណើរការនេះ |
| គម្រោង AFSA (ADG/CIRD) | ការសម្របសម្រួល | ការសម្របសម្រួលសិក្ខាសាលាស្តីពីការប្រឹក្សាយោបល់ |

## 4. ដំណើរការអនុវត្តន៍

ខាងក្រោមនេះ មានការបរិយាយដំណាក់កាលសំខាន់ចម្បងៗក្នុងដំណើរការ ដែលបានកើតឡើងសម្រាប់ការត្រួតពិនិត្យក្របខណ្ឌច្បាប់៖

### 4.1. ការងារត្រៀមរៀបចំជាមួយក្រសួង MAFF និងសហព័ន្ធសហករណ៍ DGRV

គឺជាការងារសំខាន់មួយដែលមានក្នុងការរៀបចំកិច្ចពិភាក្សារវាងក្រសួង MAFF និងអ្នកតំណាងកសិករ។ ដំបូង គេចាំបាច់ត្រូវទាក់ទាញនាយកដ្ឋាន DACP និងអង្គការអន្តរជាតិនានាដែលគាំទ្រដំណើរការបង្កើតបទបញ្ញត្តិនេះ ឱ្យចូលរួមក្នុងដំណើរការប្រឹក្សាយោប់ជាក់ស្តែង ដើម្បីបង្កើតជាអនុក្រឹត្យ និងឯកសារច្បាប់ផ្សេងទៀត។ គេត្រូវធ្វើកិច្ចប្រជុំជា

ច្រើន នៅមុនពេលក្រុមការងាររបស់គម្រោង SCCRP និងសហព័ន្ធអង្គការកសិករអាចទទួលបានច្បាប់ចម្លងសេចក្តីព្រាងបទបញ្ញត្តិ ដូច្នេះពួកគេអាចចាប់ផ្តើមដំណើរការប្រឹក្សាយោបល់បាន។

## 4.2. ការរៀបចំសិក្ខាសាលាស្តីពីការប្រឹក្សាយោបល់៖

ជាដំបូង ដើម្បីធានាប្រសិទ្ធភាពនៃការប្រឹក្សាយោបល់ និងគុណភាព និងភាពជាតំណាងនៃការចូលរួមចំណែករបស់អ្នកដឹកនាំអង្គការកសិករ គេបានព្យាករណ៍ថា ត្រូវរៀបចំឱ្យមានការប្រឹក្សាយោបល់តុមូលនៅថ្នាក់ខេត្ត ដើម្បីអាចឱ្យអ្នកតំណាងសហព័ន្ធអង្គការ FO ប្រឹក្សាយោបល់ជាមួយសមាជិករបស់ខ្លួនជាមុនសិន មុននឹងចូលរួមក្នុងសិក្ខាសាលាស្តីពីការប្រឹក្សាយោបល់នេះ។ ប៉ុន្តែ រឿងនេះមិនអាចធ្វើបានទេ ដោយសារក្រសួង MAFF បានកំណត់កាលបរិច្ឆេទកំណត់តឹងតែងពេក។ នៅទីបញ្ចប់ គេបានសម្រេចថា ត្រូវរៀបចំតែសិក្ខាសិលាមួយស្តីពីការប្រឹក្សាយោបល់នៅទីក្រុងភ្នំពេញ នាថ្ងៃទី 29 ខែកញ្ញា ឆ្នាំ 2014 ដែលសម្របសម្រួលដោយ ប្រាក់ សេរីវឌ្ឍ ជាប្រធាន CIRD ទទួលខុសត្រូវលើការគាំទ្រដល់ការបង្កើតមុខងារការពាររបស់សហព័ន្ធ FO សម្រាប់គម្រោង AFSA ដែលបានមូលនិធិពីរដ្ឋាភិបាល បែលស៊ិក (the DGD) ។

អ្នកតំណាង 9 នាក់មកពី FAEC និង 6 នាក់មកពី FCFD បានជួបប្រជុំនៅថ្ងៃនោះ ដើម្បីវិភាគខ្លឹមសារឯកសារព្រាង ហើយការណែនាំត្រូវបានរៀបរាប់យ៉ាងលម្អិតដូចខាងក្រោម៖

- ការកែប្រែជំពូក 2 (ទស្សនវិស័យ បេសកកម្ម គោលបំណង និងទិសដៅ) ដើម្បីឱ្យ AC-U សម្រេចចិត្ត និងបង្កើតទស្សនវិស័យ បេសកកម្ម គោលបំណង និងទិសដៅផ្ទាល់ខ្លួនរបស់ពួកគេ។ ពួកគេបានស្នើថាជំពូក 2 ត្រូវបានរក្សាទុក ប៉ុន្តែត្រូវបានបញ្ជាក់យ៉ាងច្បាស់ជាគោលការណ៍ណែនាំ និងសេចក្តីណែនាំពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដោយគ្មានកាតព្វកិច្ចសម្រាប់សមាជិក AC-U ទេ។
- ការបន្ថែមលើមាត្រា 17 (សិទ្ធិ និងតួនាទីរបស់គណៈកម្មាធិការត្រួតពិនិត្យផ្ទៃក្នុង) នៃជំពូក 3 (អ្នកដឹកនាំ និងគណៈគ្រប់គ្រង) ក្នុងការផ្អាកសមាជិករបស់គណៈកម្មាធិការរដ្ឋបាល AC-U ក្នុងករណីមានផលវិបាកដែលនឹងមានផលប៉ះពាល់អវិជ្ជមានលើផលចំណេញរបស់ AC-U ។ លើសពីនេះទៀត គណៈកម្មការត្រួតពិនិត្យផ្ទៃក្នុងនឹងត្រូវបញ្ជូនរបាយការណ៍ប្រចាំឆ្នាំរបស់ពួកគេទៅមហាសន្និបាត AC-U ។
- ការកែប្រែមាត្រា 19 (តម្លៃ និងលក្ខណៈវិនិច្ឆ័យស្នូលនៃសមាជិកភាព) នៃជំពូក 4 ដើម្បីបញ្ជាក់ថា តួអង្គ AC-U គួរតែជាអ្នកតំណាងរបស់ AC មិនដូចជាកសិករសមាជិកម្នាក់ៗទេ។
- ការកែប្រែមាត្រា 21 (កិច្ចការរបស់សមាជិក) ដើម្បីបញ្ជាក់ផ្នែក 5 ថាអ្នកតំណាង AC ផ្តល់យោបល់យ៉ាងមុតមាំថា AC-U នឹងបើកចំហរចំពោះការវិនិយោគសហគ្រាសក្នុងវិស័យឯកជន ហើយដៃគូផ្សេងៗ ដើម្បីពង្រឹងការប្រាស្រ័យទាក់ទង និងជំរុញឱ្យមានការគាំទ្រគ្រប់ប្រភេទ (គាំទ្រផ្នែកចំណេះដឹង បច្ចេកទេស និងហិរញ្ញវត្ថុ)។ ក្នុងផ្នែក 8 មិនមានភាពច្បាស់លាស់ថានរណានឹងផ្តល់សំណងទៅនរណាក្នុងករណីមានការខូចខាតទេ។
- ការបញ្ជាក់លក្ខណៈវិនិច្ឆ័យលើការជ្រើសរើសសម្រាប់ប្រធាន AC-U ក្នុងមាត្រា 23 (តម្លៃ និងលក្ខណៈវិនិច្ឆ័យស្នូលរបស់ប្រធាន) និងការបញ្ជាក់ពីកម្រិតនៃចំណេះដឹង/ការអប់រំ
- បញ្ជាក់អំពីទំនួលខុសត្រូវលើបំណុលក្នុងមាត្រា 33

- អ្នកតំណាង AC បានស្នើសុំរចនាសម្ព័ន្ធវិមិជ្ឈការសម្រាប់ការគ្រប់គ្រង។ សំណើនេះគឺដើម្បីផ្តល់សិទ្ធិអំណាចដល់គណៈកម្មាធិការរដ្ឋបាល ដែលបំពេញដោយគណៈកម្មាធិការត្រួតពិនិត្យផ្ទៃក្នុង អ្នកផ្តល់ប្រឹក្សា និងនាយកប្រតិបត្តិ ដូចបានបង្ហាញលើតារាងខាងក្រោម៖

**រូបភាពទី 1 ៖ តារាងរៀបចំដែលបានស្នើសម្រាប់សហគមន៍**




នៅចុងបញ្ចប់នៃសិក្ខាសិលានោះ អ្នកតំណាង AC រៀបចំកិច្ចប្រជុំមួយទៀតនៅថ្ងៃទី 9 ខែតុលា ឆ្នាំ 2014 ហើយក៏មានការសម្របសម្រួលពី AFSA ដើម្បីព្រាងគំរូបទបញ្ញត្តិផ្ទៃក្នុងសម្រាប់ AC-U ផងដែរ។ ប៉ុន្តែដោយសារតែសហព័ន្ធ FO មិនបានទទួលមតិត្រឡប់ពី MAFF ពាក់ព័ន្ធនឹងការងារត្រួតពិនិត្យឡើងវិញរបស់ពួកគេទេ ដូច្នេះពួកគេបានសម្រេចចិត្តផ្លាស់ប្តូររបៀបវារៈកិច្ចប្រជុំ ដើម្បីផ្តោតលើការងាររៀបចំនៃសកម្មភាពគាំទ្រដោយសហព័ន្ធ FO ក្នុងព្រឹត្តិការណ៍សំខាន់ៗដែលបានរៀបចំឡើងដោយរដ្ឋាភិបាល។

## 4.3. ការប្រាស្រ័យទាក់ទងលើលទ្ធផលនៃសិក្ខាសាលា៖

FAEC បានបញ្ជូនលទ្ធផលពីសិក្ខាសាលាតាមអ៊ីមែលជាភាសាខ្មែរទៅ DACP នៅថ្ងៃទី 13 ខែតុលា ឆ្នាំ 2014 ។ MAFF បានឆ្លើយតបនៅថ្ងៃបន្ទាប់ថា ពួកគេនឹងផ្តល់ជាតុចូលទៅក្រុមស្នូលរបស់ MAFF ។ FAEC បានឆ្លើយតបតាមអ៊ីមែលថា ពួកគេចង់បានមតិត្រឡប់អំពីការរួមចំណែករបស់ពួកគេ។ វាជាការលំបាកសម្រាប់តំណាង FAEC/FCFD ក្នុងការផ្តល់មតិដោយគ្មានការបញ្ជាក់អត្ថន័យ និងការបកស្រាយ ហើយ FAEC បានស្នើសុំការប្រជុំមួយជាមួយ DACP/MAFF ម្តងទៀតនៅថ្ងៃទី 11 ខែវិច្ឆិកា ឆ្នាំ 2014 ដើម្បីទទួលបានមតិត្រឡប់ និងបង្កើតទឡ្ហីករណ៍របស់ពួកគេបន្ថែម និងធ្វើការបញ្ជាក់។ ប៉ុន្តែ សំណើសុំប្រជុំនេះនៅតែមិនទាន់មានចម្លើយពី MAFF ទេ ហើយពួកគេមិនអាចទទួលបានឱកាសនេះ ដើម្បីបង្ហាញមតិ និងការណែនាំដោយផ្ទាល់ស្តីពីបទបញ្ញត្តិព្រាងនេះបានទេ។

# 5. លទ្ធផល និងស្ថានភាពប្រតិបត្តិការ

ការប្រឹក្សាយោបល់ជាមួយវិស័យឯកជន និងសង្គមស៊ីវិលគឺនៅមិនទាន់ជាផ្នែកមួយច្បាស់លាស់ និងជាក់ស្តែងរបស់ដំណើរការបង្កើតគោលនយោបាយ និងបទបញ្ញត្តិសម្រាប់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទទេ ដែលជាទូទៅ

បានបង្ហាញពីភាពស្ទាក់ស្ទើរមួយចំនួនក្នុងការអនុញ្ញាតឱ្យសហព័ន្ធអង្គការ FO រៀបចំដំណើរការប្រឹក្សាយោបល់ផ្ទៃក្នុងដោយរបស់ពួកគេដោយផ្ទាល់ ដោយគ្មានការគ្រប់គ្រង ឬការអន្តរាគមន៍ពីក្រសួងឡើយ។

ដូចនេះ ការមិនឆ្លើយតបរបស់ DACP ចំពោះសំណើរបស់ FAEC សម្រាប់កិច្ចប្រជុំបានបង្ហាញពីការខ្វះខាតនៃវប្បធម៌សន្ទនា និង/ឬខ្វះការពិចារណាសម្រាប់សហព័ន្ធអង្គការ FO ។ នៅក្នុងឱកាសជាច្រើនលើក ដែលសមភាគីរបស់ក្រសួងកសិកម្ម រុក្ខាប្រម៉ាញ់ និងនេសាទ នៅក្នុងគម្រោង SCCRP បានលើកឡើងថា ក្រសួងកសិកម្មមិនធ្វើការជាមួយសហព័ន្ធអង្គការ FO ទេ ដោយសហព័ន្ធទាំងនេះបានចុះបញ្ជីជាសមាគមន៍នៅក្នុងក្រសួងមហាផ្ទៃ ដូច្នេះ វានៅក្រៅដែនសមត្ថកិច្ចរបស់ក្រសួងកសិកម្ម។ ប៉ុន្តែការទទ្បឹករណ៍នេះមិនមានការពាក់ព័ន្ធទេ ដោយសារតែក្រសួងកសិកម្មមិនធ្វើការជាមួយក្រុមហ៊ុនវិស័យឯកជនដែលបានចុះបញ្ជីនៅក្រសួងពាណិជ្ជកម្ម ហើយមានសិទ្ធិក្នុងការធ្វើការជាមួយភាគីពាក់ព័ន្ធទាំងអស់ដែលទាក់ទងនឹងវិស័យកសិកម្មទេ។ ទោះយ៉ាងណាក៏ដោយ ដំណើរការប្រឹក្សាយោបល់សម្រេចបានយ៉ាងជោគជ័យ ប្រកបដោយគុណភាពប្រសើរក្នុងកិច្ចសន្ទនាលក្ខណៈឯកជន និងសាធារណៈ។ DGRV បានលើកឡើងថាការស្នើសុំកែលម្អភាគច្រើននូវឯកសារច្បាប់របស់សហករ AC-U ក៏ត្រូវបានលើកឡើងដោយអ្នកប្រឹក្សាយោបល់របស់ពួកគេដែរ ដោយបង្ហាញថាការងាររបស់សហព័ន្ធអង្គការ FO-Fed គឺពោរពេញទៅដោយគុណភាពល្អ។

**រូបភាពទី 2 ៖ ចំនួនមតិណែនាំ ពីសហព័ន្ធ FO ត្រូវបានយកមកពិចារណាយ៉ាងម៉ត់ចត់ដោយក្រសួង MAFF ក្នុងការបញ្ចប់បទបញ្ញត្តិស្តីពីសហជីពនៃសហករណ៍កសិកម្ម**




រូបភាពទី 2 (ទល់មុខ) បង្ហាញថា ទោះបីជាមានភាពស្ទាក់ស្ទើរមួយចំនួនពីក្រសួង MAFF ក្នុងដំណើរការប្រឹក្សាយោបល់ក៏ដោយ ផ្នែក (តូច) មួយនៃការផ្តល់មតិ និងការណែនាំដែលបង្កើតឡើងដោយសហព័ន្ធ FO ត្រូវបានយកមកពិចារណាផ្នែកខ្លះ ឬទាំងស្រុង នៅពេលផ្លាស់ទីពីសេចក្តីព្រាងដំបូងទៅជាកំណែផ្លូវការចុងក្រោយនៃប្រកាសស្តីពីសហជីពសហករណ៍កសិកម្ម និងឧបសម្ព័ន្ធរបស់ខ្លួន។

ការកែលម្អសមត្ថភាពរបស់អ្នកតំណាង AC ដែលបានទទួលស្គាល់ក្នុងការវិភាគ និងពិភាក្សាអំពីគោលនយោបាយ និងបទបញ្ញត្តិដែលបានស្នើឡើងនឹងពិតជាជួយកសាងទំនុកចិត្ត និងចំណាប់អារម្មណ៍សម្រាប់ការប្រឹក្សាយោបល់នាពេលអនាគត នៅពេលបញ្ហាទាំងនេះកើតឡើង។

បទពិសោធន៍នេះបានបញ្ជាក់អំពីគុណភាពនៃការសន្ទនាសាធារណៈ និងឯកជនដែលបានធ្វើឡើងក្នុងឆ្នាំ 2014 ។ តួនាទីរបស់អ្នកសម្របសម្រួលខាងក្រៅគឺមានសារៈសំខាន់ក្នុងការកែលម្អកិច្ចសន្ទនានេះ ព្រោះតែបច្ចេកទេសសម្របសម្រួល និងផ្នែកជំនួយបច្ចេកទេសបានធ្វើឱ្យសិក្ខាសាលាមានភាពរស់រវើក និងមានផលិតភាព។ ការយល់ដឹង និងចំណាប់អារម្មណ៍របស់អ្នកចូលរួមត្រូវបានលើកឡើង ដើម្បីកែលម្អស្ថានភាពអាជីវកម្មកាន់តែប្រសើរឡើង។

SCCRP ▪ ករណីសិក្សា

# 6. អត្ថប្រយោជន៍

ជារួម មិនថាសំខាន់ ឬអត់ទេ សហករណ៍ AC (និងសហគ្រាស) អាចដឹងថាសក្តានុពលទីផ្សាររបស់ពួកគេដែលពឹងផ្អែកធំធេងលើលក្ខខណ្ឌទូទៅនៃការធ្វើអាជីវកម្ម។ ការគាំទ្រដល់សន្ទនាសាធារណៈ និងឯកជនលក្ខណៈស្ថាប័ន ត្រូវបានទទួលស្គាល់ថាជាអត្ថប្រយោជន៍ដ៏សំខាន់មួយសម្រាប់ក្រុមហ៊ុនទាំងអស់ដែលនឹងទទួលពីបរិយាកាសវិនិយោគ និងអាជីវកម្មវិជ្ជមាន។

អត្ថប្រយោជន៍មួយទៀតនៃសិក្ខាសាលាស្តីពីការយោបល់ ពេលដែលការសិក្សាទាំងនេះត្រូវបានអនុវត្តត្រឹមត្រូវ នោះវាគឺជាចំណេះដឹងដែលទទួលបានពីអ្នកតំណាងរបស់ FO ក្នុងអំឡុងពេលធ្វើការវិភាគ និងប្រាស្រ័យទាក់ទង។ ដូច្នេះ យុទ្ធនាការផ្សព្វផ្សាយស្តីពីច្បាប់ជាក់លាក់គឺមិនមានភាពចាំបាច់ទេ ឬនៅកម្រិតកាត់បន្ថយ។ ដំណើរការប្រឹក្សា យោបល់ដែលមានការរៀបចំល្អនឹងចំណាយតិចជាងយុទ្ធនាការផ្សព្វផ្សាយ។